**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ៤៤៩/២៤ **ក.ប/ខ.ល**

## សារលិខិតអបអរសាទរ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា**

**និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

ក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយទឹកចិត្តសោមនស្សរីករាយ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមសម្តែងនូវអំណរសាទរយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសទទួលបាន «**ពានរង្វាន់សតវត្សរ៍អាស៊ី** ICAPP» នាអំឡុងពេលមហាសន្និបាតលើកទី១២ នៃសន្និសីទអន្តរជាតិនៃគណបក្សនយោបាយនៅអាស៊ី នាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤ ដែលជាពានរង្វាន់ដ៏មានកិត្យានុភាព និងជាសក្ខីភាពមួយសម្រាប់ការទទួលស្គាល់ និងការគោរពចំពោះការចូលរួមចំណែកដ៏ធំធេងរបស់ **សម្តេចតេជោ** នាពេលកន្លងមកក្នុងការពង្រឹងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការផ្នែកនយោបាយ ក្នុងចំណោមសមាជិកជាគណបក្សនយោបាយ និងដៃគូរបស់ ICAPP មកពីជុំវិញពិភពលោក ក្នុងកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកសុខសន្តិភាព និងវិបុលភាពសម្រាប់ប្រជាជន។

«**ពានរង្វាន់សតវត្សរ៍អាស៊ី** ICAPP» ដែលត្រូវបានប្រគល់ជូន **សម្តេចតេជោ** គឺពិតជាស័ក្តិសមបំផុតចំពោះ **សម្តេចតេជោ** ក្នុងការដឹកនាំនាវាកម្ពុជានាអាណត្តិកន្លងមក ប្រកបដោយគតិបណ្ឌិត និងមានចក្ខុវិស័យវែងឆ្ងាយ និងជាបិតាសន្តិភាពដែលបានរំដោះប្រទេសជាតិចេញផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ឈានដល់ការផ្សះផ្សាបង្រួបបង្រួមជាតិក្រោមនយោបាយ "ឈ្នះ-ឈ្នះ" នាំមកនូវសុខសន្តិភាពស្ថិរភាពនយោបាយ លទ្ធិប្រជាធិបតេយ្យ ឯករាជ្យជាតិ អធិបតេយ្យភាពដែនដី និងការអភិវឌ្ឍប្រទេសលើគ្រប់វិស័យ ព្រមទាំងលើកកម្ពស់នូវកិត្តិនាមជាតិឱ្យល្បីរន្ទឺលើឆាកអន្តរជាតិ។

ឆ្លៀតក្នុងឱកាសដ៏មហាមង្គលាភិរម្យថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្វសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ ជូនចំពោះ **សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវភក្តីភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ អង្គារ ១១រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង ស្ួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩